**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៨ . អនក្រ. បក

# អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិបណ្ដុះបណ្ដាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិបណ្ដុះបណ្ដាល
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រាមួយ**

មាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិបណ្ដុះបណ្ដាល ត្រូវបានកែសម្រួលដូចតទៅ :

- សមាសភាពនៃគណៈកម្មាធិការជាតិបណ្ដុះបណ្ដាលមានដូចខាងក្រោម :

១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធាន

| | | |
|---|---|---|
| ២. | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣. | តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៤. | តំណាងក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥. | ប្រធានសភាមុខរបរ និងមីក្រូសហគ្រាស | អនុប្រធាន |
| ៦. | តំណាងនិយោជក | អនុប្រធាន |
| ៧. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩. | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០. | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១. | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២. | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៣. | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៤. | តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១៥. | តំណាងក្រសួងកិច្ចការនារី | សមាជិក |
| ១៦. | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៧. | តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៨. | តំណាងក្រសួងផែនការ | សមាជិក |
| ១៩. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២០. | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ២១. | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២២. | តំណាង ៤រូប របស់និយោជក | សមាជិក |
| ២៣. | តំណាង ១រូប របស់សភាពាណិជ្ជកម្ម | សមាជិក |
| ២៤. | តំណាង ២រូប របស់និយោជិត | សមាជិក |
| ២៥. | តំណាង ៣រូប ជាអ្នកផ្តល់ការបណ្តុះបណ្តាល | សមាជិក |
| ២៦. | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | នាយកប្រតិបត្តិ |

- គណៈកម្មាធិការជាតិអាចអញ្ជើញតំណាង ៣រូប របស់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ចូលរួមបាន។

- គណៈកម្មាធិការជាតិនេះមាន អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍។

**មាត្រា៣**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៤**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង គណៈកម្មាធិការជាតិបណ្តុះបណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៤*
- *ឯកសារ- កាលប្បវត្តិ*